YUNNAN DAILY PRESS GROUP
No.191

ប្រទេសចិន-ខេត្តយូនណាន

ទស្សនៈកម្ពុជា

khmerlight@163.com
english.yunnan.cn

ឆ្នាំទី27 លេខ7989 ថ្ងៃសុក្រ ទី26 ខែកក្កដា ឆ្នាំ2019

ប្រទេសចិនប្រកាសរបាយការណ៍សេដ្ឋកិច្ចឆមាសទី១ ឆ្នាំ២០១៩ : ប្រទេសចិនសម្រេចកំណើនសេដ្ឋកិច្ច៦,៣ភាគរយ



កម្មករកំពុង ពិនិត្យគុណភាពរថយន្តក្នុងរោងចក្រផលិតរថយន្តម៉ាក "ទង់ដំរី" ក្នុងទីក្រុងឆាង់ឈុននៃខេត្តជីលីន

តាមស្ថិតិពីអាជ្ញាធរជាតិស្ថិតិចិនដែលប្រកាសនៅថ្ងៃទី១៥ ខែកក្កដា ឆ្នាំ ២០១៩ នៅឆមាសទី ១ នៃឆ្នាំ ២០១៩ ទំហំ GDP របស់ប្រទេសចិនមានចំនួន៤៥.០៩៣.៣០០លានយាន់ កើនឡើង៦,៣ភាគរយ បើប្រៀបធៀបនឹង រយៈពេលដូចគ្នានៅឆ្នាំ២០១៨ ។ លោក ម៉ា ស៊ីងយ៉ុងអ្នកនាំពាក្យព័ត៌មាននៃអាជ្ញាធរជាតិស្ថិតិចិនបានបញ្ជាក់ថា និយាយជាទូទៅប្រទេសចិនបានរក្សាកំណើនសេដ្ឋកិច្ច ដែលមានលក្ខណៈសមហេតុផលនៅឆមាសទី១ នៃឆ្នាំ ២០១៩ ដែលបានរក្សានូវនិន្នាការអភិវឌ្ឍន៍ដែលប្រកបដោយស្ថិរភាព ។

-កំណើនGDP :៦,៣ ភាគរយ

នៅឆមាសទី១នៃឆ្នាំ២០១៩ប្រទេសចិនបានសម្រេចកំណើន GDP ៦,៣ ភាគរយ ។ បើគូបធៀបនឹងសូចនាការអំពីការផ្តល់ឱកាសការងារនិងតម្លៃទំនិញជាដើមប្រទេសចិនបានរក្សាកំណើនសេដ្ឋកិច្ចដែលមានលក្ខណៈសមហេតុផល និងបានជាប់លំដាប់ថ្នាក់ឈានមុខក្នុងចំណោមសេដ្ឋកិច្ចសំខាន់ផ្សេងៗ លើពិភពលោក ។

-ការវិនិយោគ:កើនឡើង៥,៨ ភាគរយ

នៅឆមាសទី១ នៃឆ្នាំ ២០១៩ ទំហំវិនិយោគលើអចលនទ្រព្យទូទាំងប្រទេសចិនបានកើនឡើង៥,៨ភាគរយ បើប្រៀបធៀបនឹងរយៈពេលដូចគ្នានៅឆ្នាំ២០១៨ ។ នៅខែមិថុនាទំហំវិនិយោគលើអចលនទ្រព្យបានកើនឡើង0,៤៤ភាគរយ ។ ការវិនិយោគលើវិស័យឧស្សាហកម្មផលិតកម្មបច្ចេកទេសកម្រិតខ្ពស់បានកើនឡើង១០,៤ ភាគរយ ដែលមានកំណើនខ្ពស់ជាងកំណើននៃការវិនិយោគទូទៅ៤,៦ ភាគរយ ។ ការវិនិយោគលើវិស័យសេវាកម្មបច្ចេកទេសកម្រិតខ្ពស់បានកើនឡើង១៣,៥ភាគរយដែលមានកំណើនខ្ពស់ជាងកំណើននៃការវិនិយោគទូទៅ ៧,៧ភាគរយ ។

-ការចំណាយ :ពាណិជ្ជកម្មលក់រាយប្រដាប់ប្រើប្រាស់ប្រចាំថ្ងៃមានទំហំសរុបជិត២០ទ្រីលានយាន់

នៅឆមាសទី១ ឆ្នាំ២០១៩ ពាណិជ្ជកម្មលក់រាយប្រដាប់ប្រើប្រាស់ប្រចាំថ្ងៃក្នុងសង្គមចិនមានទំហំសរុប ១៩.៥២១.០០០លានយាន់ កើនឡើង ៨,៤ភាគរយ ។ ក្នុងចំណោមការចំណាយលើវិស័យផ្សេងៗ របស់ប្រជាពលរដ្ឋចិនការចំណាយលើវិស័យសេវាកម្មមានចំនួន៤៩,៤ភាគរយ កើនឡើង0,៦ភាគរយ បើប្រៀបធៀបនឹងរយៈពេលដូចគ្នានៅឆ្នាំ២០១៨ ។ ទំហំនៃការលក់រាយតាមបណ្តាញអ៊ីនធឺណិតមានចំនួន៤.៨១៦.១០០លានយាន់ កើនឡើង ១៧,៨ភាគរយ ។

-ពាណិជ្ជកម្មអន្តរជាតិ: ទំហំនាំចេញនាំចូលកើនឡើង៣,៩ភាគរយ

ក្រោមបរិការណ៍ដែលប្រទេសចិននិងអាម៉េរិកមានការប៉ះទង្គិចគ្នាលើវិស័យពាណិជ្ជកម្មប្រទេសចិនបានសម្រេចទំហំពាណិជ្ជកម្មនាំចេញនាំចូល ១៤,៦៧ទ្រីលានយាន់នៅឆមាសទី១ នៃឆ្នាំ ២០១៩កើនឡើង ៣,៩ភាគរយ ។ ក្នុងនោះការនាំចេញមានទំហំ ៧៩៥ ទ្រីលានយាន់ កើនឡើង ៦,១ភាគរយ ចំណែកការនាំចូលមានទំហំ ៦,៧២ ទ្រីលានយាន់ កើនឡើង ១,៤ភាគរយ ។

-ទុនវិនិយោគបរទេស: ក្រុមហ៊ុនទុនវិនិយោគបរទេសដែលទើបបង្កើតជាថ្មីមានចំនួនជាង២ម៉ឺនក្រុមហ៊ុន

តាមទិន្នន័យពីក្រសួងពាណិជ្ជកម្មចិនបានឱ្យដឹងថា ក្នុងអំឡុងពេលពីខែមករាដល់ខែមិថុនាឆ្នាំនេះក្រុមហ៊ុនទុនវិនិយោគបរទេសដែលទើប បង្កើតជាថ្មីនៅប្រទេសចិនមានចំនួន២០.១៣១ ក្រុមហ៊ុនដែលប្រើទុនវិនិយោគ បរទេស ៤៧៨.៣៣០លានយាន់ប្រាក់ចិនកើនឡើង៧,២ភាគរយ ។

-ចំណូល :កើនឡើង ៨,៨ ភាគរយ

នៅឆមាសទី១ នៃឆ្នាំ ២០១៩ ចំណូលជាមធ្យមរបស់ប្រជាជនទូទាំងប្រទេសចិនមានចំនួន១៥.២៩៤យាន់ កើនឡើង៦,៥ភាគរយ(គិតបញ្ចូលនូវកត្តាតម្លៃទំនិញ) ខ្ពស់ជាងកំណើន GDP ០,២ភាគរយ ។ អត្រាប្រៀបធៀបរវាងចំណូលប្រជាជនក្នុងទីក្រុងនិងនៅតំបន់ជនបទ គឺ២,៧៤ ។ អត្រាកំណើនចំណូលប្រជាជននៅតំបន់ជនបទមានកម្រិតខ្ពស់ជាងប្រជាជនក្នុងទីក្រុង ។

-ការផ្តល់ឱកាសការងារ: ផ្តល់ឱកាសការងារថ្មីដល់ប្រជាជន ៧,៣៧លាននាក់

នៅឆមាសទី១ នៃឆ្នាំ ២០១៩ ប្រទេសចិនបានផ្តល់ឱកាសការងារថ្មីដល់ប្រជាជន៧,៣៧លាននាក់ សម្រេចគោលដៅប្រចាំឆ្នាំ៦៧ភាគរយ ។ នៅខែមិថុនា អត្រាអត់ការងារធ្វើក្នុងទីក្រុងទូទាំងប្រទេសចិនគឺ៥,១ភាគរយ ក្នុងនោះ អត្រាអត់ការងារធ្វើរបស់ប្រជាជនដែលមានអាយុពី២៥ ឆ្នាំដល់ ៥៩ ឆ្នាំគឺ ៤,៦ភាគរយ ។ នៅឆមាសទី១ វិស័យសេវាកម្មនៃប្រទេសចិនបានរក្សានិន្នាការកើនឡើងយ៉ាងល្អប្រសើរ ។ វិស័យសេវាកម្មអំពីការបញ្ជូនព័ត៌មានសូហ្វវែល និងព័ត៌មានវិទ្យាបានកើនឡើង២០,៦ភាគរយចំណែក សូចនាការនៃសេវាកម្មចិនបានកើនឡើង៧,៣ ភាគរយ ។

-តម្លៃទំនិញ :សូចនាការ CPI កើនឡើង២,២ភាគរយ

នៅឆមាសទី១ នៃឆ្នាំ ២០១៩ សូចនាការ CPI របស់ប្រទេសចិនបានកើនឡើង២,២ភាគរយ ។ លោក លីវ-ស្យេជឺ អ្នកសិក្សាស្រាវជ្រាវជាន់ខ្ពស់មកពីមជ្ឈមណ្ឌលសិក្សាស្រាវជ្រាវហិរញ្ញវត្ថុនៃធនាគារគមនាគមន៍ចិនបានលើកឡើងថា កត្តាដែលអាចធ្វើឱ្យសូចនាការ CPI កើនឡើងខ្ពស់សុទ្ធតែមានភាពអន់ខ្សោយ ។ នៅឆមាសទី ២ នៃឆ្នាំ២០១៩ CPI មិនអាចកើនឡើងខ្ពស់ទេ ហើយគ្មានសម្ពាធជាក់ច្បាស់អំពីអតិផរណាទេ ។

-ឧស្សាហកម្មផលិតកម្ម:តម្លៃបន្ថែមនៃផលិតកម្មបច្ចេកទេសកម្រិតខ្ពស់កើនឡើង៩ភាគរយ

នៅឆមាសទី១ នៃឆ្នាំ ២០១៩ តម្លៃបន្ថែមនៃផលិតកម្មបច្ចេកទេសកម្រិតខ្ពស់កើនឡើង៩ភាគរយ បើប្រៀបធៀបនឹងរយៈពេលដូចគ្នានៃឆ្នាំ ២០១៨ ដែលមានល្បឿនកំណើនខ្ពស់ជាងឧស្សាហកម្មដែលមានទ្រង់ទ្រាយធំ៣ ភាគរយ ។ ផលិតកម្មរថយន្តអាគុយ និងអាគុយថាមពលពន្លឺព្រះអាទិត្យ បានកើនឡើង៣៤,៦ភាគរយ និង២០,១ ភាគរយរៀងខ្លួន ។ ការវិនិយោគលើវិស័យផលិតកម្មបច្ចេកទេសកម្រិតខ្ពស់របស់ប្រទេសចិនបានកើនឡើង ១០,៤ភាគរយ ចំណែកការវិនិយោគលើវិស័យសេវាកម្មបច្ចេកទេសបានកើនឡើង១៣,៥ភាគរយ ។

គោលដៅប្រចាំឆ្នាំនៃការអភិវឌ្ឍសេដ្ឋកិច្ចរបស់ប្រទេសចិនគឺរក្សាកំណើនសេដ្ឋកិច្ច៦-៦,៥ភាគរយ។កំណើន៦,៣ ភាគរយ នៅឆមាសទី ១នេះបានកសាងមូលដ្ឋានគ្រឹះយ៉ាងរឹងមាំសម្រាប់ការសម្រេចគោលដៅប្រចាំឆ្នាំ ។

១ឆ្នាំ២០១៩ : ...

...

...

##